ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ០៩ អយក.សណន

# សេចក្តីណែនាំ
## ស្តីពី
## ការពង្រឹងការអនុវត្តតេស្តស្តង់ដាតាមលំនាំតេស្តស្តង់ដាកម្រិតអន្តរជាតិ PISA នៅតាមគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ

ក្នុងគោលបំណងលើកកម្ពស់ចំណេះដឹង និងបំណិនផ្នែកអំណាន គណិតវិទ្យា និងវិទ្យាសាស្ត្រ របស់សិស្សនៅមធ្យមសិក្សា ព្រមទាំងជំរុញការបង្រៀន និងរៀន តាមលំនាំសំណួរតេស្តស្តង់ដាកម្រិតអន្តរជាតិ PISA ក្រសួងអប់រំ យុវជន និងកីឡាសូមធ្វើការណែនាំដល់អង្គភាពពាក់ព័ន្ធ គណៈកម្មការគ្រប់គ្រងគ្រឹះស្ថានមធ្យមសិក្សា និងលោកគ្រូ អ្នកគ្រូ ដូចខាងក្រោម៖

**១. អង្គភាពថ្នាក់ជាតិ** មានដូចជានាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងគម្រោងពាក់ព័ន្ធ៖

- ផ្តល់ជូនគំរូសំណួរតេស្តអន្តរជាតិ PISA ផ្នែកអំណាន គណិតវិទ្យា និងវិទ្យាសាស្ត្រ ជាទម្រង់ PDF ព្រមទាំងតំណភ្ជាប់ ដើម្បីដំឡើងកម្មវិធីស្វ័យហ្វឹកហាត់ GEIP EdTech ជូនដល់គ្រប់គ្រឹះស្ថានមធ្យមសិក្សាសាធារណៈ
- ផ្សព្វផ្សាយ និងចុះបង្ហឹកការធ្វើតេស្តស្តង់ដាតាមលំនាំសំណួរតេស្តអន្តរជាតិ PISA តាមគ្រប់មធ្យោបាយ
- ជំរុញការតាក់តែងសំណួរតេស្តស្តង់ដា តាមលំនាំសំណួរតេស្តអន្តរជាតិ PISA បន្ថែមថ្មីជាប្រចាំ ដោយត្រូវបន្សីសេចក្តីពន្យល់កម្រិតសមត្ថភាពទាំង ៦ នៃតេស្តអន្តរជាតិ PISA ជាមួយនឹងលទ្ធផលសិក្សារំពឹងទុកនៃកម្មវិធីសិក្សាលម្អិតប្រចាំខែផ្អែកលើលក្ខណៈបច្ចេកទេស៖
    - អំណានត្រូវផ្តោតលើ លំនាំគិត អត្ថបទ និងស្ថានភាព
    - គណិតវិទ្យាត្រូវផ្តោតលើ លំនាំដោះស្រាយ ខ្លឹមសារគណិតវិទ្យា និងបរិបទ
    - វិទ្យាសាស្ត្រត្រូវផ្តោតលើ សមត្ថភាព ឥរិយាបថ បរិបទ និងចំណេះដឹង
- ចុះគាំទ្រសាលារៀន និងគ្រូបង្រៀន ឱ្យបានទៀងទាត់ និងមានផែនការច្បាស់លាស់ ដោយផ្តោតលើដំណើរការហ្វឹកហាត់សំណួរតេស្តអន្តរជាតិ PISA ។

**២. គណៈគ្រប់គ្រងគ្រឹះស្ថានមធ្យមសិក្សា**

- ប្រមូល និងចងក្រងសំណួរតេស្តស្តង់ដាតាមលំនាំតេស្តអន្តរជាតិ PISA
- ជំរុញការអនុវត្តតេស្តស្តង់ដានៅកម្រិតសាលារៀន


អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

- ដាក់បញ្ចូលគំរូសំណួរតេស្តអន្តរជាតិ PISA ដែលមានស្រាប់ និងតាក់តែងថ្មី នៅក្នុងការធ្វើតេស្តស្តង់ដាកម្រិតសាលារៀន ឬវាយតម្លៃការសិក្សាដើមឆ្នាំ ប្រចាំខែ ត្រីមាស ឆមាស និងចុងឆ្នាំ
- រៀបចំក្លឹបសិក្សាតេស្តអន្តរជាតិ PISA សម្រាប់សិស្សគ្រប់កម្រិតថ្នាក់នៅតាមសាលារៀន ដើម្បីហ្វឹកហាត់គំរូសំណួរតេស្តអន្តរជាតិ PISA ក្នុងកម្មវិធីស្វ័យហ្វឹកហាត់ GEIP EdTech និងលើសន្លឹកវិញ្ញាសាជាសកម្មភាពនៃកម្មវិធីក្រៅម៉ោងសិក្សា ដោយមានបញ្ជីឈ្មោះសិស្ស និងរបាយការណ៍ក្លឹបសិក្សា
- បូកសរុប និងផ្សព្វផ្សាយលទ្ធផលនៃការហ្វឹកហាត់សំណួរតេស្តអន្តរជាតិ PISA តាមមុខវិជ្ជាគ្រប់កម្រិតថ្នាក់ នៅក្នុងកិច្ចប្រជុំប្រចាំខែឱ្យបានទៀងទាត់ ព្រមទាំងរក្សាទុកឯកសារ និងរបាយការណ៍ជាភស្តុតាងក្នុងការពិនិត្យតាមដាន និងវាយតម្លៃ

**៣. គ្រូបង្រៀន**

- ក្រុមបច្ចេកទេសមុខវិជ្ជាត្រូវពិភាក្សា និងរៀបចំវិធីសាស្ត្របង្រៀនថ្មីៗឱ្យឆ្លើយតបនឹងសំណួរតេស្តអន្តរជាតិ PISA
- ពិភាក្សាពីការបញ្ជ្រាបការបង្រៀនឱ្យឆ្លើយតបនឹងសំណួរតេស្តអន្តរជាតិ PISA ដើម្បីដាក់បញ្ចូលក្នុងកិច្ចតែងការបង្រៀននៅគ្រប់មេរៀន និងគ្រប់កម្រិតថ្នាក់ ក្នុងកិច្ចប្រជុំបច្ចេកទេសមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា
- រៀបចំថ្នាក់និទស្សន៍អនុវត្តសាកល្បងការបង្រៀនឱ្យឆ្លើយតបនឹងសំណួរតេស្តអន្តរជាតិ PISA ដើម្បីឆ្លុះបញ្ចាំងអំពីសកម្មភាពបង្រៀនកន្លងមក និងដើម្បីកែលម្អការបង្រៀនឱ្យកាន់តែប្រសើរឡើង
- ចូលរួមក្នុងការតាក់តែងសំណួរតេស្តអន្តរជាតិ PISA បន្ថែមថ្មីជាប្រចាំ
- អនុវត្តការបង្រៀនឱ្យឆ្លើយតបនឹងសំណួរតេស្តអន្តរជាតិ PISA និងប្រើប្រាស់គំរូសំណួរតេស្តអន្តរជាតិ PISA ដែលមានស្រាប់ និងតាក់តែងថ្មីក្នុងវាយតម្លៃការសិក្សាដើមឆ្នាំ ប្រចាំខែ ត្រីមាស ឆមាស និងចុងឆ្នាំ។

ទទួលបានសេចក្តីណែនាំនេះ គ្រឹះស្ថានមធ្យមសិក្សាសាធារណៈ ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ខណ្ឌ ស្រុក មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត លោកគ្រូ អ្នកគ្រូ និងគ្រប់ភាគីពាក់ព័ន្ធ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ចន្ទ ៥កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- អគ្គលេខាធិការដ្ឋាន គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី

  *"ដើម្បីជ្រាបជាព័ត៌មាន"*
- កាលប្បវត្តិ
- ឯកសារ នា.អធិការកិច្ចគុណភាពអប់រំ

t.ly/sfuJh

គំរូវិញ្ញាសាតេស្តអន្តរជាតិ PISA